## របាយការណ៍ស្តីអំពីទស្សនកិច្ចនៅទ្វីបអឺរ៉ុប ពីថ្ងៃទី១៤ ដល់ ២៤ ខែធ្នូ ឆ្នាំ២០០៧ របស់ លោក កឹម សុខា - លោក ប៉ែន សុវណ្ណ ប្រធាន និង អនុប្រធានគណបក្សសិទ្ធិមនុស្ស

លោក **កឹម សុខា** - លោក **ប៉ែន សុវណ្ណ** ប្រធាន និង អនុប្រធានគណបក្សសិទ្ធិមនុស្ស បានអញ្ជើញមកដល់ទីក្រុងប៉ារីស៍ពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ដោយមានការចូលរួមរបស់ព្រះអង្គ **នាថបណ្ឌិតោ ឫទ្ធិពល** និមន្តមកពីសហរដ្ឋអាមេរិកផង ដើម្បីជួបសហគមន៍ខ្មែរនៅអឺរ៉ុប ឥស្សរជនជាន់ខ្ពស់បារាំង អង្គការក្រៅរដ្ឋាភិបាល និង អ្នកកាសែតបារាំង ។

រាល់ការជួបទាំងអស់លោកប្រធាន **កឹម សុខា** តែងតែលើកពន្យល់ ស្តីអំពីស្ថានការណ៍ នយោបាយ-សេដ្ឋកិច្ច-សង្គមកិច្ច-សិទ្ធិមនុស្ស នៅប្រទេសខ្មែរ និងស្តីអំពី ចក្ខុវិស័យ គោលបំណង គោលការណ៍ របស់គណបក្សសិទ្ធិមនុស្ស និងស្នើសុំឲ្យមានការចូលរួមពីសហគមន៍ខ្មែរនៅអឺរ៉ុប ។

លោកប្រធាន **កឹម សុខា** ក៏បានស្នើសុំឲ្យឥស្សរជនជាន់ខ្ពស់បារាំង អង្គការក្រៅរដ្ឋាភិបាល និង អ្នកកាសែតបារាំង ជួយជំរុញ ត្រួតពិនិត្យ និង សង្កេតការណ៍ដល់យន្តការនៃការបោះឆ្នោត នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខាងមុខនេះឲ្យមានភាពសុក្រិត និង យុត្តិធម៌ ។

### កម្មវិធីជំនួប

- ថ្ងៃសុក្រ ទី១៤ : ●ពេលល្ងាច ជួបសំណេះសំណាលជាមួយបងប្អូនខ្មែរយើងនៅទីក្រុង Vaires Sur Marne ជាយក្រុងប៉ារីស៍
- ថ្ងៃសៅរ៍ ទី១៥ : ●ពេលព្រឹក មហាសន្និបាតលើកទី១ របស់គណបក្សសិទ្ធិមនុស្សប្រចាំទ្វីបអឺរ៉ុប នៅទីក្រុងប៉ារីស៍ ហើយអង្គសន្និបាតបានពិនិត្យពិភាក្សាយ៉ាងល្អិតល្អន់ រួចបានអនុម័តជាឯកច្ឆ័ននូវ លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង រួចបានបោះឆ្នោតជ្រើសតាំងលោក **លឹមប៊ុន ស៊ីដារ៉េត** ជាប្រធានគណបក្សសិទ្ធិមនុស្សប្រចាំទ្វីបអឺរ៉ុប សំរាប់អាណត្តិទី១ រយៈពេល ២ឆ្នាំ

  ●ពេលល្ងាច ប្រជុំជូនពត៏មាននៅទីក្រុងប៉ារីស៍ ក្រោមអធិបតីភាព លោក **កឹម សុខា** និង លោក **ប៉ែន សុវណ្ណ** ដោយមានការចូលរួមរបស់ព្រះអង្គ **នាថបណ្ឌិតោ ឫទ្ធិពល** និមន្តមកពីសហរដ្ឋអាមេរិក ស្តីអំពីស្ថានការណ៍ នយោបាយ-សេដ្ឋកិច្ច-សង្គមកិច្ច-សិទ្ធិមនុស្ស នៅប្រទេសខ្មែរ និងស្តីអំពី ចក្ខុវិស័យ គោលបំណង និងគោលការណ៍ របស់គណបក្សសិទ្ធិមនុស្ស

- ថ្ងៃអាទិត្យ ទី១៦ : •ពេលព្រឹក ជួបសំណេះសំណាលជាមួយបងប្អូនខ្មែរយើងនៅទីក្រុង Bruxelles ប្រទេស Belgique
  •ជួបលោក Frédéric Loeung អតីតអភិបាលគំរោងជាន់ខ្ពស់សហភាពអឺរ៉ុប
  •ពេលល្ងាច ជួបសំណេះសំណាលជាមួយបងប្អូនខ្មែរយើងនៅប្រទេស Hollande
- ថ្ងៃច័ន្ទ ទី១៧ : •ម៉ោង ២ រសៀល ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោក Jean-Marie FARDEAU - នាយកការិយាល័យប៉ារីស៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស
- ថ្ងៃអង្គារ ទី១៨ : •ម៉ោង ៩ ព្រឹក ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោក Axel PONIAPOWSKI - ប្រធានគណៈកម្មាធិការកិច្ចការបរទេសរបស់រដ្ឋសភាបារាំង
  •ម៉ោង ១២ ថ្ងៃត្រង់ ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោក Vincent BROSSEL - នាយកការិយាល័យអាស៊ីប៉ាស៊ីហ្វិក(Asie pacifique) របស់អង្គការយកពត៌មានគ្មានព្រំដែន (Reportage Sans Frontières)
  •ម៉ោង ២ រសៀល ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោក Gustave BAIBLE - នាយកការិយាល័យកិច្ចការអាស៊ីរបស់អង្គការអាំនែស្ទីអន្តរជាតិ (Amnesty International)
- ថ្ងៃពុធ ទី១៩ : •ម៉ោង ១០ ព្រឹក ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោកស្រី Chantal BRUNEL - ប្រធានក្រុមមិត្តភាពបារាំងកម្ពុជា និង លោក Jacques Bouvet de la Maisonnauve - ក្រសួងកិច្ចការអន្តរជាតិ និងការពារជាតិ របស់រដ្ឋសភាបារាំង
  •ម៉ោង ៣ រសៀល ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោក Fabrice MAURIES - ក្រសួងការបរទេសបារាំងទទួលបន្ទុកកិច្ចការអាស៊ីភាគអគ្នេយ៍ (Asie du Sud Est) និង លោក Florent AYDALOT - ក្រសួងការបរទេសបារាំងទទួលបន្ទុក កិច្ចការ កម្ពុជា លាវ វៀតណាម
- ថ្ងៃព្រហស្បតិ៍ ទី២០ : •ម៉ោង ១០ ព្រឹក ផ្តល់កិច្ចសម្ភាសន៍នៅទីក្រុងប៉ារីស៍ជាមួយលោក Jean-François TAIN - នាយការិយាល័យវិទ្យុអន្តរជាតិបារាំង ខេមរៈភាសា RFI
  •ម៉ោង ១២ ថ្ងៃត្រង់ ផ្តល់កិច្ចសម្ភាសន៍ដល់វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA)
  •ម៉ោង ២ រសៀល ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោកស្រី

Isabelle BRACHET - នាយិកាការិយាល័យអន្តរជាតិអាស៊ីរបស់អង្គការសម្ព័ន្ធភាពអន្តរជាតិដើម្បីសិទ្ធិមនុស្ស

- ថ្ងៃសុក្រ ទី២១ : ●ម៉ោង ៩ ព្រឹក ផ្តល់កិច្ចសម្ភាសន៍នៅទីក្រុងប៉ារីស៍ជាមួយលោកស្រី Christine CHAUMEAU - ការិយាល័យអន្តរជាតិ ផ្នែកអាស៊ីភាគអគ្នេយ៍ (Asie du Sud-Est) របស់សារពត៌មាន Courrier International

●ម៉ោង ១០ ព្រឹក ផ្តល់កិច្ចសម្ភាសន៍នៅទីក្រុងប៉ារីស៍ជាមួយលោក Dorian MALOVIC - ការិយាល័យអន្តរជាតិ ផ្នែកអាស៊ី របស់សារពត៌មាន La Croix

●ម៉ោង ២ រសៀល ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោកស្រី Christine DESOUCHES - ទីប្រឹក្សាពិសេសទទួលបន្ទុកនយោបាយ និងការទូតរបស់អង្គការអន្តរជាតិខាងភាសាបារាំង (Francophonie)

●ម៉ោង ៤ រសៀល ជួបសំណេះសំណាលនៅទីក្រុងប៉ារីស៍ជាមួយលោកស្រី Alexandra VELEVA – អ្នកទទួលខុសត្រូវផ្នែកផែនការរបស់ អង្គការអន្តរជាតិខាងភាសាបារាំង (Francophonie)

- ថ្ងៃសៅរ៍ ទី២២ : ●ពេលព្រឹក ជួបសំណេះសំណាលជាមួយបងប្អូនខ្មែរយើង និងប្រជុំជូនពត៌មាននៅទីក្រុង Rennes

●ផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកសារពត៌មាន Ouest France តំបន់ Ille et Vilaine

●ពេលល្ងាច ជួបសំណេះសំណាលជាមួយបងប្អូនខ្មែរយើង និងប្រជុំជូនពត៌មាននៅទីក្រុង Lorient

●ផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកសារពត៌មាន Ouest France តំបន់ Morbihan

- ថ្ងៃអាទិត្យ ទី២៣ : ●ម៉ោង ១០ ព្រឹក សម្ភាសន៍ឆ្លើយឆ្លងវេទិកាសេរីជាមួយបងប្អូនខ្មែរតាមវិទ្យុលីយ៉ុង Radio Lyon

●ម៉ោង ២ រសៀល ចូលរួមបុណ្យផ្កានៅ **វត្តពោធិវង្ស** ដែលរៀបចំឡើងដោយសកម្មជនរបស់គណបក្សសិទ្ធិមនុស្ស នៅប្រទេសបារាំង

●ពេលល្ងាច ជួបសំណេះសំណាលជាមួយបងប្អូនខ្មែរយើងនៅទីក្រុង Torcy ជាយក្រុងប៉ារីស៍

- ថ្ងៃច័ន្ទ ទី២៤ : ●ម៉ោង ១ រសៀល លោក **ឃឹម សុខា** និង លោក **ប៉ែន សុវណ្ណ** បានអញ្ជើញវិលត្រឡប់ទៅកាន់មាតុប្រទេសយើងវិញ បន្ទាប់ពីបានបំពេញទស្សនកិច្ចប្រកបដោយជោគជ័យនៅទ្វីបអឺរ៉ុប ដោយមានការគាំទ្រយ៉ាងច្រើនកុះករពីសហគមន៍ខ្មែរនៅអឺរ៉ុប

P.D.H - BP 33 - 92320 CHATILLON Tél. : 0609384616 - 0621131701 - 0661858668 E-mail : eurohrpcambodia@yahoo.com

និង ការទទួលយ៉ាងយកចិត្តទុកដាក់ពីសំណាក់ឥស្សរជនជាន់ខ្ពស់បារាំង អង្គការក្រៅរដ្ឋាភិបាលបារាំង និងអន្តរជាតិ និងអ្នកសារពត៌មានបារាំង ។

ធ្វើនៅប៉ារីស៍ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៧

**លឹមប៊ុន ស៊ីដារ៉េត**
ប្រធានគណបក្សសិទ្ធិមនុស្សប្រចាំទ្វីបអឺរ៉ុប